# ជំពូក ៨

# សន្និដ្ឋាន និង អនុសាសន៍

## Conclusions and Recommendations

Draft

# ជំពូកទី ៨

# សន្និដ្ឋាន និង អនុសាសន៍

## ៨.១ សន្និដ្ឋាន

ការវាយតំលៃបរិស្ថាន និងសង្គមដំបូងលើគំរោងវិនិយោគសំរាប់អភិវឌ្ឍន៍វារីអគ្គិសនីកំចាយខេត្តកំពត របស់ក្រុមហ៊ុន SINOHYDRO Corporation Limited. ដែលក្រុមហ៊ុនបានអោយ SAWAC Consultants for Development ធ្វើការសិក្សាស្រាវជ្រាវដើម្បីរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមដំបូងនេះអាចធ្វើសេក្តីសន្និដ្ឋានដូចតទៅ :

ក្រុមហ៊ុនបោះវិនិយោគ មានទឹកប្រាក់ចំនួន ២៨០លានដុល្លាសហរដ្ឋអារិក ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ដែល តំណាងឱ្យរាជរដ្ឋាភិបាលបានចុះកិច្ចសន្យា យល់ព្រមឱ្យក្រុមហ៊ុនវិនិយោគលើគំរោងវារីអគ្គិសនីកំចាយ ខេត្តកំពត ប្រភេទគំរោង BOT (Build Operation Transfer) នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ (កិច្ចសន្យាមានចែងក្នុងឧបសម្ព័ន្ធ ១) ។

㊀ គំរោងនេះនឹងធ្វើអោយបាត់បង់ទាំងស្រុងនូវ ព្រៃស្រោង ដែលមានផ្ទៃដី ១៤១៧.៥៦ហិកតា និងព្រៃល្បាយឫស្សី ដែលមានផ្ទៃដី ១៣៩.៧៤ហិកតា (ពិពណ៌នា លំអិតនៅក្នុងជំពូក.៤ កថាខ័ណ្ឌ ៤.២.៤ ផែនទីលេខ ៣ និងជំពូក ៥ កថាខ័ណ្ឌ ៥.៣.២.២) ។

㊁ គំរោងនេះអាចមានការប៉ះពាល់ដល់សត្វព្រៃ និងជំរករបស់វា (មានចែងក្នុងជំពូក ៤ កថាខ័ណ្ឌ ៤.២.៥) ក៏ប៉ុន្តែក្រុមហ៊ុននឹងបង្កលក្ខណៈងាយស្រួលសំរាប់ការបំលាស់ទីរបស់ជីវៈចំរុះទាំងនោះ ទៅកន្លែងព្រៃឧទ្យានជាតិ បូកគោដែលនៅជាប់គ្នានេះ ។

㊂ អាចនឹងប៉ះពាល់ដល់ការប្រើប្រាស់កាន់កាប់ដីរបស់ប្រជាពលរដ្ឋក្នុងតំបន់ទឹកឈូប្រមាណ ១១០ហ.ត រួមមាន មានដីចំការចំនួន ១៩ម្ចាស់ នៅផ្នែកខាងស្តាំស្ទឹង និងមានដីចំការចំនួន ១៣ម្ចាស់ នៅផ្នែកខាងឆ្វេងស្ទឹង ដោយសាររចនាសម្ព័ន្ធតំបន់ទំនប់ទីពីរ (រាប់ចាប់ពីទំនប់ទីពីរ រហូតដល់ស្ពានដែក) ។ ជាងនេះទៀតមានកម្មករចំនួន៣៨គ្រួសារ ដែលកំពុងធ្វើចំការនិងរស់នៅលើដីទាំងនោះ ហើយដែលនឹងប្រឈមនឹងការបាត់បង់ការងារ និងជំរករស់នៅរបស់គាត់ ។

គំរោងក៏នឹងមានបញ្ហាចំពោះសិទ្ធប្រើប្រាស់ទឹក ជាមួយអ្នកប្រើប្រាស់ទឹកក្នុងព្រែកទឹកឈូទាំងអស់ ជាពិសេសអាចមានបញ្ហាចោទខ្លាំងបង្គរជាមួយរដ្ឋាករទឹកក្រុងកំពត លើភាពមិនប្រក្រតីនៃបរិមាណ និងគុណភាពប្រភពទឹក ។

ប្រភពទឹកលើដី (អូរ ព្រែក) ក្នុងតំបន់គំរោងខ្សែទឹកខាងលើ មិនទាន់មានការបំពុលពីសកម្មភាពរបស់មនុស្សទេ ។ ទោះបីជាមាន ប៉ារ៉ាម៉ែត្រមួយចំនួនលើសពី ស្តង់ដាគុណភាពទឹករបស់ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល និង ស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈ សំរាប់រក្សាជីវសាស្ត្រចំរុះ របស់ក្រសួងបរិស្ថានក៏ដោយ ព្រោះវាកើតចេញពីធម្មជាតិ ក្នុងតំបន់គំរោងនេះតែប៉ុណ្ណោះ ។ តែនៅខ្សែទឹកខាងក្រោមចាប់ពីកន្លែងកំសាន្តទឹកឈូ ចុះមកក្រោម ឃើញមានសញ្ញានៃសកម្មភាពបំពុលពីមនុស្ស សំណល់រាវរឹងពីទីក្រុង និងទឹកប្រៃជោរចូលមក ។

Draft

គំរោងនេះពុំមានហេតុប៉ះពាល់ធ្ងន់ធ្ងរទៅលើបរិស្ថាននិងសង្គមទេ ពីព្រោះក្រុមហ៊ុនបានរៀបចំវិធានការកាត់បន្ថយនូវការប៉ះពាល់អវិជ្ជមានឱ្យដល់កំរិតអប្បបរមាទៅតាមដែលក្រុមហ៊ុនមានបទពិសោធន៍ជាច្រើនឆ្នាំនៅប្រទេសចិន និងបណ្តាប្រទេសកំពុងអភិវឌ្ឍមួយចំនួនទៀត។ ជាឧទាហរណ៍សង្ខេបពីវិធានការការពារ និងកាត់បន្ថយ សំរាប់សំណល់ដែលមានសារធាតុប្រេង និង សារធាតុគីមី ឬ សំណល់រឹងផ្សេងៗទៀត ក្រុមហ៊ុននិងទុក ដាក់គ្រប់គ្រងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។ បន្ថែមពីលើនេះក្រុមហ៊ុននឹងបំពាក់ឧបករណ៍សំអាតទឹក ក្រខ្វក់ដែលមានសមត្ថភាពគ្រប់គ្រាន់យោងតាមការបញ្ចេញចោលរបស់គំរោងនេះ ។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុននឹង សហការជាមួយក្រសួង បរិស្ថាន និងស្ថាប័នពាក់ព័ន្ធ ក្នុងការត្រួតពិនិត្យ និង ផ្តល់យោបល់លើសកម្មភាពនៃការ គ្រប់គ្រងសំណល់រឹង និងរាវជាប្រចាំ ។ ប៉ុន្តែគំរោងវារីអគ្គិសនីកំចាយនេះអាចនឹងមានហានិយភ័យកំរិតខ្ពស់ ដូចជាការបាក់ភ្នំ ការបាក់ទំនប់ជាដើម ក្នុងពេល សាងសង់ និងពេលដំណើរការ ដូចមានរាយរាប់លំអិតក្នុងជំពូក ៥នៃរបាយការនេះ ។

ទន្ទឹមនឹងផលប៉ះពាល់អវិជ្ជមានដល់ធនធានធម្មជាតិ និងបរិស្ថានសង្គមមួយចំនួន គំរោងក៏នឹងផល់ផលប្រយោជន៍យ៉ាងសន្ធឹកសន្ធាប់ដល់ប្រជាជនមូលដ្ឋាន និងសង្គមជាតិទាំងមូលផងដែរ ដូចជា -:

ប្រទេសកម្ពុជានឹងមានទំនប់វារីអគ្គិសនីធំជាងគេ (១៩៣ MGW) លើដំបូងនៅក្នុងប្រវត្តិសាស្ត្រសង្គមជាតិដែលសមត្ថភាពរបស់វាអាចផលិតថាមពលអគ្គិសនីបាន ៤៨៨ ជីហ្គាវ៉ាត់ម៉ោង (GWh) គឺប្រមាណជា ៦៧% នៃថាមពលអគ្គិសនីដែលប្រទេសកម្ពុជាផលិតបានសរុបនៅឆ្នាំ២០០៤ ហើយគំរោងវារីអគ្គិសនីកំចាយនឹងផ្តល់ថាមពល អគ្គសនីយ៉ាងចំបងអាចឆ្លើយតបដ៏មានប្រសិទ្ធភាព ចំពោះដំណោះស្រាយប្រភពអគ្គិសនីសំរាប់ប្រទេសកម្ពុជា ក្នុងរយៈពេល មធ្យម ។ នៅពេលគំរោងនេះដំណើរការ ប្រទេសកម្ពុជានឹងមានថាមពលអគ្គិសនី ទ្វេរដងនៃកំលាំងថាមពល អគ្គិសនីផលិតសរុបក្នុងឆ្នាំ ២០០៥ ។ ជាងនេះទៀតគំរោងវារីអគ្គិសនីកំចាយ នឹងផ្តល់ស្ថេរភាពក្នុងការផ្គត់ផ្គង់ភ្លើងអគ្គិសនីដល់អ្នកប្រើបាស់ តាមរោងចក្រឧស្សាហកម្មនានា លំនៅដ្ឋាន ទីសាធារណៈ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិកម្ពុជា ដើម្បីរំដោះភាពក្រីក្ររបស់ប្រជាជនក្នុងតំបន់គំរោង និងទូទាំងប្រទេស ព្រមទាំងធ្វើអោយសង្គមជាតិរីកចំរើនលើគ្រប់វិស័យ ។

តាមរយៈគំរោងនេះនឹងផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជាប្រមាណ ៨០០នាក់ ក្នុងតំណាក់កាលសាងសង់ និងមួយចំនួនតូចទៀតនៅពេលប្រតិបត្តិការនិងថែទាំ ។ គំរោងនឹងបង្កើតប្រាក់ចំណូលដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានតាមរយៈចូលបំរើការ ជាបុគ្គលិក កម្មករ ទាំងពេលសាងសង់ និងពេលប្រតិបត្តិការថែទាំ ។ ដោយសារឥទ្ធិពលនៃការអភិវឌ្ឍន៍គំរោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វា អាចបង្កើនចំណូលដល់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានតាមរយៈទេសចរជាតិ និងអន្តរជាតិ ក្នុងតំបន់ទឹកឈូ និងការទស្សនាទំនប់វារីអគ្គិសនីកំចាយនេះទៀតផង ។

គំរោងវារីអគ្គិសនីកំចាយ អាចជួយបន្ថយជំនន់ធំៗក្នុងតំបន់ភ្នំកំចាយនេះបានមួយផ្នែក ។ បើជំនន់ដើមរដូវវស្សាអាចទប់បានមួយផ្នែកធំ តែបើជំនន់ចុងរដូវវស្សា នោះអាចទប់បានមួយផ្នែកតូចប៉ុណ្ណោះ ។ បើគំរោងមានការប្រលែងបញ្ចេញទឹកពីទំនប់ទីពីរ ៥ម$^{៣}$/វិនាទី ទៀងទាត់ឥតដាច់ នៅរដូវប្រាំង នោះធ្វើអោយព្រែកកំពង់បាយមានលំនឹងបរិស្ថានល្អប្រសើរ និងទប់ស្កាត់ការជ្រាបចូលជ្រៅនៃទឹកប្រៃពីសមុទ្រមកតំបន់ទឹកឈូ ដែលផ្តល់ប្រយោជន៍យ៉ាងច្រើនដល់ការប្រើប្រាស់ទឹកសាបសំរាប់ស្រោចស្រពដំណាំ ការកំសាន្ត និងជាពិសេសការផ្គត់ផ្គង់ទឹកស្អាត របស់រដ្ឋាករទឹកក្រុងកំពត ។

Draft

បរិមាណដ៏ធំធេងនៃអាងទាកទាំងពីរអាចបង្កលក្ខខ័ណ្ឌសមស្របសំរាប់ការអភិរក្ស និងការកើនឡើងនៃប្រភេទត្រីមួយចំនួនធំក្នុងតំបន់ស្ទឹងកំចាយនេះ ។

គំរោងនេះនឹងមានសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងតំបន់នេះ ដូចជា កែលំអផ្លូវចេញចូលតំបន់ទឹកឈូអោយមានលក្ខណៈល្អប្រសើរ សាងសង់ផ្លូវនិងស្ពានចេញចូលពីការដ្ឋានយកថ្ម ផ្លូវជុំវិញអាង ស្តុកទឹកទាំងពីរ ។ល។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធបំរើអោយសាធរណជន គំរោងមានសាងសង់អគារស្នាក់នៅអោយបុគ្គលិកកម្មករ ការិយាល័យ សួនច្បារ និងអាងលេងទឹកសំរាប់ការប្រើប្រាស់របស់បុគ្គលិកគំរោង និងធ្វើអោយមានសោភណ្ឌភាពដល់ តំបន់គំរោងទាំងមូលទៀតផង ។

ដោយសារឥទ្ធិពលនៃការអភិវឌ្ឍន៍គំរោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វា អាចនឹងធ្វើអោយដីក្នុងតំបន់កើនតំលៃខ្ពស់ជាងបច្ចុប្បន្ននេះ (២០០៦) ជាពិសេសការប្រើប្រាស់ដីសំរាបវិស័យឧស្សាហកម្ម កសិកម្មទំនើប និងទេសចរណ៍ ។ ដោយសារហេដ្ឋារចនាសម្ព័ន្ធរបសគំរោង់ អាចទាក់ទាញអ្នកទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនានៅក្នុងតំបន់គំរោង តំបន់ទឹកឈូ តំបន់បូកគោ និងតំបន់ក្បែរខាង ទៅថ្ងៃអនាគតយ៉ាងសន្ធឹកសន្ធាប់ទៀតផង ហើយនឹងធ្វើអោយខេត្តកំពតទាំងមូលក្លាយជាប៉ូលទេសចរណ៍យ៉ាងសំខាន់មួយ សំរាប់ប្រទេសកម្ពុជាយើងផងដែរ ។

គំរោងមានការបង់ផ្ទាល់ចូលចំណូលថវិកាជាតិ ដោយសារក្រុមហ៊ុននឹងត្រូវបង់ពន្ធអាករ លើការនាំចូលប្រេងឥន្ធនះសំរាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀត ក្នុងរយៈពេលប្រតិបត្តិការនិងថែទាំគំរោង ទៅតាមកិច្ចសន្យារវាងក្រុមហ៊ុន ជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

## ៨.២ អនុសាសន៍

ដើម្បីទទួលបានភាពរលូនក្នុងការអនុវឌ្ឍន៍គំរោងវារីអគ្គិសនីកំចាយ និងពង្រឹងភាពទទួលខុសត្រូវចំពោះកិច្ចអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តភាពលើធនធានធម្មជាតិ និងសុវត្ថិភាពសង្គម នោះតាមរយៈការសិក្សាវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមដំបូងសំរាប់គំរោងវារីអគ្គិសនីនេះ SAWAC សូមផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដូចតទៅ -:

- ក្រុមហ៊ុនត្រូវសិក្សារចនាប្លង់នៃសមាសភាពគំរោងទាំងអស់ ដែលធានាដល់ភាពល្អប្រសើរតាមលក្ខណៈបច្ចេកទេស និងកាត់បន្ថយផលប៉ះពាល់ដីធ្លី លំនៅដ្ឋាន និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង ។

- រដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងពាក់ព័ន្ធ ត្រូវដោះស្រាយបញ្ហាការបាត់បង់ដីធ្លី លំនៅដ្ឋាន ទ្រព្យសម្បត្តិស្របច្បាប់របស់ប្រជាពលរដ្ឋ និងមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគេ ទៅតាមផ្លូវច្បាប់ និងតាមស្ថានភាពជាក់ស្តែង ដោយមិនបំពារបំពានលើ ប្រជាពលរដ្ឋដែលរងគ្រោះដោយសារសកម្មភាពគំរោងវារីអគ្គិសនីកំចាយនេះ ។

- ក្រុមហ៊ុនត្រូវធ្វើសហប្រតិបត្តការយ៉ាងពេញទំហឹង (ទាំងថវិការ និងបច្ចេកទេស) ជាមួយឧទ្យានជាតិបូកគោ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការដាំព្រៃឈើឡើងវិញក្នុងតំបន់

Draft

ក្បែរខាងគំរោង ដើម្បីទូទាត់ ការបាត់បង់ព្រៃឈើដែលជាជំរកសត្វព្រៃ និងលំនឹងបរិស្ថាននៃឧទ្យានជាតិបូកគោ ដោយសារសកម្មភាពគំរោង ។

- ក្រុមហ៊ុនត្រូវធ្វើកិច្ចពិភាក្សាជាមួយរដ្ឋាករទឹក និងមន្ទីរឧស្សាហកម្មខេត្តកំពត ព្រមទាំងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីផ្លាស់ប្តូរទីតាំងស្ថានីយ៍បូមទឹក (Intake Station) ទៅនៅក្នុងតំបន់អាងទីពីរ ដែលជាមធ្យោបាយប្រសើរបំផុតសំរាប់ ដោះស្រាយបញ្ហាគុណភាពទឹក និងកង្វះទឹក ។

- គំរោងគួរតែរចនាប្លង់អោយមានការបញ្ចេញទឹកពីទំនប់ទីពីរមកខ្សែទឹកខាងក្រោម ដោយធានានូវបរិមាណចារទឹកយ៉ាងតិចបំផុត ៦ម³/វិនាទី យ៉ាងទៀងទាត់ឥតដាច់នៅរដូវប្រាំង ដើម្បីធ្វើអោយព្រែកនេះមានលំនឹងបរិស្ថានកាន់តែប្រសើរ និងបញ្ចៀសបាននូវការហូរចូលមកនូវទឹកប្រៃក្នុងតំបន់ទឹកឈូនោះ ។

- ក្រុមហ៊ុនត្រូវមានការប្រុងប្រយ័ត្ន និងត្រៀមគ្រប់គ្រងហានិភ័យអោយបានកំរិតខ្ពស់ ដូចជា ការសិក្សាភូគព្ភសាស្ត្រ និងបរិស្ថានក្នុងតំបន់គំរោងអោយបានហ្មត់ចត់ ការរចនាប្លង់ គុណភាពសំណង់ធានាបានមិនអោយមានការបាក់ទំនប់ បាក់ភ្នំ ។ ត្រៀមគ្រប់គ្រងហេតុការណ៍ដែលអាចកើតឡើងចៃដន្យ ដោយប្រព័ន្ធផ្សព្វផ្សាយគ្រប់គ្រាន់ និងទាន់ពេលវេលា អ្នកជួយសង្គ្រោះ និងសំភារៈសង្គ្រោះ ព្រមទាំងថវិកាសំរាប់ដោះស្រាយជាបន្ទាន់ទៀតផង ។

ជាទីបញ្ចប់នេះ ក្រុមហ៊ុន SINOHYDRO Corporation Limited. ដែលជាម្ចាស់គំរោងវិនិយោគ សំរាប់អភិវឌ្ឍន៍វារីអគ្គិសនីកំចាយ ខេត្តកំពត គឺមានឱកាសផ្តល់នូវផលប្រយោជន៍ជាច្រើនដល់រាជរដ្ឋាភិបាល និងជាពិសេសដល់ប្រជាពលរដ្ឋ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និង អភិវឌ្ឍន៍របស់ប្រទេសជាតិ ។ ដូចនេះក្រុមហ៊ុនមានសំណូមពរដល់ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធមួយចំនួនទៀត ព្រមទាំងរាជរដ្ឋាភិបាលកម្ពុជា មេត្តាជួយបង្ក លក្ខណៈងាយស្រួល និងចេញលិខិតអនុញ្ញាតិឱ្យក្រុមហ៊ុនស្របតាមច្បាប់វិនិយោគ និងច្បាប់កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិបានទាន់ពេលវេលាដែលបានគ្រោងទុកយ៉ាងពិតប្រាកដ ។

រាជធានីភ្នំពេញ, ថ្ងៃទី.........ខែ................ឆ្នាំ ២០០៦

**នាយកក្រុមហ៊ុន**

Draft